Australian Government
Department of Health

# មេរៀនសម្រាប់ប្រជាជាតិអូស្ត្រាលីពីការកើនឡើងនៃជំងឺកូវីដ-១៩ របស់ទីក្រុងមែលប៊ន

ការកើនឡើងនៃមេរោគរីករាលដាល កូវីដ-១៩ នៅក្នុងតំបន់នៃទីក្រុងមែលប៊ន គឺជាការសោកស្ដាយដែលយើងទាំងអស់គ្នាមិនបានគិតទុកពីមុន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏យើងបានរំពឹងទុកថាថ្ងៃណាមួយយើងនឹងមានករណីនេះត្រឡប់មកវិញ។ វាការពិតណាស់ នេះជាមេរៀន និងជាការពញ្ញាក់ស្មារតីទៅកាន់ជនរួមជាតិទាំងមូល។

វាជាការសំខាន់ណាស់ដែលយើងបានរៀនពីមេរៀននៃជំងឺនេះ បើមិនដូច្នោះទេយើងទាំងគ្នានឹងប្រថុយប្រថាន និងបង្កគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋទូទាំងប្រទេសអូស្ត្រាលី ប៉ុន្តែអ្វីដែលសំខាន់នោះ ការខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដ-១៩នេះដែលយើងខិតខំកន្លងមកនឹងទុកជាអាសារបង់។

សារៈសំខាន់មួយដែលខ្ញុំចង់ផ្ដោតសំខាន់ ទោះបីជាយើងទទួលបានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩ ក៏ដោយ
ក៏យើងមិនទាន់ស្ថិតក្នុងដំណាក់កាលដែលយើងទាំងអស់គ្នាអាចត្រឡប់ទៅរស់នៅក្នុងជីវិតធម្មតាមុននឹងការឆ្លង នៃជំងឺរាតត្បាតនេះបានដែរ។ មេរោគនេះនៅតែរស់នៅជាមួយយើង ហើយវានឹងនៅជាមួយយើងនៅពេលខាងមុខទៀត - ប្រសិនជាយើងក្រឡេកទៅមើលស្ថានភាពអន្តរជាតិវិញ បញ្ហានេះនៅតែបន្តមាន ហើយការរីករាលដាលរបស់វាក៏កាន់តែអាក្រក់ឡើងៗ ដោយយើងពុំទាន់បានឃើញការរីកចម្រើនអ្វីមួយឡើយ។

ការរីកដុះដាលនៅទីក្រុងមែលប៊ន ជាការបង្ហាញពីរបៀបដែលជំងឺនេះងាយស្រួលផ្ទុះឡើងម្ដងទៀត នេះប្រសិនបើយើងមិនបន្តអនុវត្តការឃ្លាតឆ្ងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងរក្សាអនាម័យឱ្យបានល្អ ជាពិសេសទៅទៀតនោះលោកអ្នកត្រូវសម្រាកស្នាក់នៅក្នុងផ្ទះនៅពេលលោកអ្នកកំពុងឈឺ។ វាក៏ជាការកើនរំឭកស្មារតីទៅដល់ប្រជាពលរដ្ឋទាំងអស់គ្នាអំពីសារៈសំខាន់នៃការទាញយកកម្មវិធីទូរស័ព្ទ COVIDSafe ដែលអនុញ្ញាតឱ្យអាជ្ញាធរសុខាភិបាលអាចរកឃើញទំនាក់ទំនងជិតស្និទ្ធរបស់មនុស្សដែលបានកើតនូវជំងឺកូវីដ-១៩ ។

នៅពេលដែល “ជំងឺត្រូវបានរកឃើញ” វានឹងអនុញ្ញាតឱ្យយើងស្វែងរកបុគ្គលដែលបានឆ្លង ដែលនឹងឈានទៅរកការការពារមេរោគពីការរីករាលដាល។

ដូច្នេះហើយ តើយើងបានរៀនអ្វីខ្លះពីការកើនឡើងម្ដងទៀតរបស់ទីក្រុងមែលប៊ន**?**
មួយចំនួនធំនៃករណីថ្មីៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងការជួបជុំជាលក្ខណៈគ្រួសារ។

តើនេះអាចប្រាប់យើងអំពីអ្វីខ្លះ**?**
រឿងទាំងអស់នេះហាក់ដូចជាប្រជាពលរដ្ឋអូស្ត្រាលីយើងមួយចំនួននៅតែមិនគិតថាជំងឺកូវីដ-១៩នេះ

Australian Government

Department of Health

ជាជំងឺដែលមានគ្រោះថ្នាក់ ហើយជំងឺនេះនឹងនៅតែឆ្លងទោះបីជានៅក្នុងចំណោមមនុស្សដែលពួកគេស្គាល់ច្បាស់នេះបូកបញ្ចូលទាំងសមាជិកគ្រួសាររបស់ពួកគេក៏ដោយ។

ដោយសារការរឹតបណ្តឹងការជួបជុំគ្នាត្រូវបានបន្ធូរបន្ថយ
ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋជួបជុំគ្នានៅតាមគេហដ្ឋាននិងកន្លែងនានា ដូចជាសណ្ឋាគារ
និងភោជនីយដ្ឋានជាដើម
ប្រជាពលរដ្ឋអូស្ត្រាលីមួយចំនួននៅតែកំពុងជ្រើសរើសការទាក់ទងគ្នាទៅវិញទៅមកដោយមិនរក្សាគម្លាតពីគ្នា។
ប្រការទាំងអស់នេះធ្វើឱ្យមានហានិភ័យផ្សេងៗជាពិសេសវាបានបង្កឱ្យសមាជិកគ្រួសារចាស់ៗដែលងាយនឹងទទួលរងគ្រោះពីជំងឺនេះក៏ដូចជាសហគមន៍ទូទៅទាំងមូល។

ដូច្នេះសូមលោកអ្នក ប្រសិនបើលោកអ្នកទៅជួបជុំមិត្តភក្តិ ឬ ទទួលទានអាហារនៅកន្លែងណាមួយ ឬ
ផ្ទះរបស់នរណាម្នាក់ លោកអ្នកត្រូវប្រាកដថាលោកអ្នកបាន
និងកំពុងរក្សាគម្លាតពីគ្នាស្របទៅនឹងការណែនាំរបស់មន្ទីរសុខាភិបាល។

យើងខ្ញុំសូមលើកទឹកចិត្តឱ្យលោកអ្នកបន្តនូវការចែកចាយការណែនាំដ៏មានសារៈសំខាន់នេះជាមួយនឹងសមាជិកគ្រួសារ មិត្តភក្តិ អ្នកជិតខាង និងតាមរយៈបណ្តាញសង្គម ព្រមទាំងអាជីវកម្មនានារបស់លោកអ្នក។

ការកើនឡើងនៃជំងឺនេះរបស់ប្រជាពលរដ្ឋរស់នៅរដ្ឋវិក្តូរីយ៉ារបស់យើងក៏បានប្រាប់យើងផងដែរ
ថាយើងត្រូវបន្តធ្វើការទាំងអស់គ្នាដើម្បីទទួលបានផលប្រយោជន៍ ដែលបានមកពីការអនុវត្តគម្លាតសង្គម
និងរក្សាអនាម័យល្អ ព្រមទាំងទាញយកកម្មវិធីទូរស័ព្ទ COVIDSafe
សម្រាប់សហគមន៍ដែលភាសាអង់គ្លេសមិនមែនជាភាសានិយាយ ឬ ភាសាសរសេរកំណើត។

កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះនឹងធានាឱ្យសហគមន៍ពហុវប្បធម៌របស់យើងទាំងអស់នឹងទទួលបានព័ត៌មានទាន់ហេតុការណ៍នានាដែលទាក់ទងទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។

ជាការពិតណាស់ ព័ត៌មានសំខាន់ៗដើម្បីជួយបុគ្គល គ្រួសារ និងអាជីវកម្មត្រូវបានបកប្រែជា ៦៣ ភាសា។

ទិន្នន័យបានបង្ហាញថា មានការចូលមើលគេហទំព័រជាង ៩០០,០០០ ដែលមាននៅលើ*គេហទំព័រព័ត៌មានជំងឺកូវីដ-១៩ នៃភាសារបស់លោកអ្នក* ចាប់តាំងពីគេហទំព័រនោះត្រូវបានបង្កើតឡើង។

Australian Government

Department of Health

នាយកដ្ឋានកិច្ចការសហគមន៍ថ្នាក់ជាតិ (**Commonwealth Department of Home Affairs**) តាមរយៈមន្ត្រីទំនាក់ទំនងសហគមន៍របស់ខ្លួនបានទាក់ទងជាមួយក្រុមសហគមន៍ពហុវប្បធម៌ច្រើនជាង ៤៣០០ ដងទូទាំងផ្ទៃប្រទេសចាប់តាំងពីការចាប់ផ្តើមរាតត្បាតនៃជំងឺកូវីដ-១៩។

លើសពីនេះទៅទៀត យើងបានសង្កេតឃើញថាមនុស្សមួយចំនួនមានការព្រួយបារម្ភអំពីការធ្វើតេស្តស្វែងរកជំងឺកូវីដ-១៩ទោះបីជាពួកគេមិនត្រូវការជាចាំបាច់ក៏ដោយ។ ជាហេតុដូច្នេះខ្ញុំសូមផ្តល់ការធានាដល់ប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា៖ ការធ្វើតេស្តនៅគ្លីនិកដែលទទួលបានជំនួយពីរាជរដ្ឋាភិបាលគឺមិនត្រូវបានគិតកម្រៃ មិនត្រឹមតែប៉ុណ្ណោះលោកអ្នកក៏មិនចាំបាច់មានបណ្ណសុខភាព (**Medicare Card**)ដើម្បីធ្វើតេស្តផងដែរ។

យើងទាំងអស់គ្នានៅមានផ្លូវវែងឆ្ងាយតទៅទៀតដើម្បីកម្ចាត់ជំងឺកូវីដ-១៩ ហើយពេលនេះមិនមែនជាពេលវេលាដែលយើងត្រូវចុះចាញ់នោះទេ។ សូមលោកអ្នកបន្តរក្សាគម្លាតពីមនុស្សម្នាក់ទៅមនុស្សម្នាក់តាមការណែនាំរបស់អ្នកជំនាញ និងរក្សាអនាម័យគ្រប់ពេលវេលា។ ម្យ៉ាងវិញទៀតសូមលោកអ្នកជ្រើសយកការសម្រាកនៅផ្ទះប្រសិនជាលោកអ្នកមិនស្រួលខ្លួន។

ប្រធានផ្នែកថែទាំសុខភាព និងពេទ្យឆ្មបរបស់រាជរដ្ឋាភិបាលអូស្ត្រាលី **Alison McMillan**